ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩

# សេចក្តីប្រកាសព័ត៌មាន
# ការតែងតាំងចៅក្រមថ្មីនៅ អ.វ.ត.ក

បន្ទាប់ពីបានទទួលការតែងតាំងពីអគ្គលេខាធិការអង្គការសហប្រជាជាតិ António Guterres និងបានទទួលការអនុម័តពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមរួចមក ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ប្រោសព្រះរាជទានតែងតាំងលោក Martin Greg KAROPKIN (សហរដ្ឋអាមេរិក) ជាចៅក្រមអន្តរជាតិនៅអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

លោកចៅក្រម Karopkin ជំនួសលោកចៅក្រម Judge Jean-Marc LAVERGNE (បារាំង) ដែលបានលាឈប់ពីមុខតំណែងកាលពីដើមឆ្នាំនេះ។

លោកចៅក្រម Karopkin បានបំពេញការងារជាចៅក្រមអន្តរជាតិបម្រុងនៅអង្គជំនុំជម្រះសាលាដំបូងចាប់តាំងពីឆ្នាំ២០១៤ មក ហើយពីមុនមក គាត់ធ្លាប់បានបំពេញការងារជាចៅក្រមអន្តរជាតិបម្រុងនៅអង្គជំនុំជម្រះតុលាការកំពូលពីឆ្នាំ២០០៦ ដល់ឆ្នាំ២០០៨ និងជាចៅក្រមអន្តរជាតិនៅក្នុងបេសកកម្មរដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកូសូវ៉ូ ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៥។ មុនពេលគាត់ចូលបំពេញការងារក្នុងក្របខណ្ឌជាចៅក្រមអន្តរជាតិ លោកចៅក្រម Karopkin ធ្លាប់បានបំពេញការងារជារដ្ឋអាជ្ញារង (Assistant District Attorney) នៅក្រុង Brooklyn រដ្ឋញូយ៉ក ជាអគ្គអធិការ (Inspector-General) នៃនាយកដ្ឋានគ្រប់គ្រងឧទ្យាន និងនាយកដ្ឋានពន្លត់អគ្គិភ័យនៅទីក្រុងញូយ៉ក ជាស្នងការរងនៃនាយកដ្ឋាននគរបាលទីក្រុងញូយ៉ក ជាចៅក្រមនៅតុលាការព្រហ្មទណ្ឌទីក្រុងញូយ៉ក ជាចៅក្រមស្តីទីនៅតុលាការកំពូលរដ្ឋញូយ៉ក និងជាចៅក្រមស្តីទីនៅតុលាការគ្រួសារ។ គាត់បានទទួលសញ្ញាប័ត្របណ្ឌិតច្បាប់ ពីមហាវិទ្យាល័យច្បាប់ក្រុង Brooklyn៕

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖*

លោក នេត្រ ភក្ត្រា
ប្រធានផ្នែកកិច្ចការសាធារណៈ និងជាមន្ត្រីនាំពាក្យ
ទូរស័ព្ទចល័ត+៨៥៥(0)១២៤៨៨១៥៦
អ៊ីមែល: neth.pheaktra@eccc.gov.kh